# ការដាក់ឲ្យនៅឯកានិងការដាក់ឲ្យនៅដាច់ពីគេ

អាជ្ញាធរសុខាភិបាលសាធារណៈប្រើវិធីដាក់ឲ្យបុគ្គលនៅឯកា និងដាក់ឲ្យនៅដាច់ពីគេ ដើម្បីទប់ស្កាត់មេរោគ ឆ្លងកុំឲ្យរាលដាល នៅពេលដែលការរាតត្បាតកើតមានឡើង, ដូចជាមេរោគ SARS (សារស៍) (Severe Acute Respiratory Sydrome), TB (របេង) (Tuberculosis) ឬមេរោគឆ្លងផ្សេងៗទៀត។

- **ការដាក់ឲ្យនៅឯកា** គឺសំរាប់មនុស្សដែលមានជម្ងឺ, ហើយ
- **ការដាក់ឲ្យនៅដាច់ពីគេ** គឺសំរាប់ឲ្យមនុស្សដែល*ប្រហែលជាអាច*ឈឺក្នុងពេលឆាប់ៗ ពីព្រោះមនុស្សទាំងនោះបានមានការប៉ះពាល់ជាមួយមនុស្សដែលបានមានរោគ។

## អ្វីទៅ*ការដាក់ឲ្យនៅឯកា*នោះ ?

ការដាក់ឲ្យនៅឯកាមានន័យថា ទប់ស្កាត់មនុស្សដែលឈឺដោយមានមេរោគឆ្លងនៅឲ្យឆ្ងាយពីមនុស្សដែលមានសុខភាពល្អ។

មានមនុស្សភាគច្រើនបានសម្រេចចិត្តនៅឯកាម្នាក់ឯងនៅក្នុងផ្ទះ នៅពេលពួកគេឈឺដើម្បីការពារសមាជិក ក្រុមគ្រួសារនិងអ្នកដទៃទៀត។ ទុកកូនឲ្យនៅផ្ទះមិនឲ្យទៅរៀននៅសាលានៅពេលក្មេងមានរោគអុតតូចនេះគឺជាឧទាហរណ៍នៃការដាក់ឲ្យនៅឯកា។ ចំពោះអ្នកជម្ងឺដែលមានមេរោគខ្លះៗ, ដូចជារោគ TB (របេង) និងរោគ SARS (សារស៍), មន្ទីរនឹងដាក់ឲ្យមនុស្សទាំងនោះនៅឯកាពីអ្នកជម្ងឺផ្សេងៗទៀត។

## តើខ្ញុំ*ត្រូវតែ*នៅឯកាម្នាក់ឯងឬ ?

បាទ/ចាស។ បើសិនជាអាជ្ញាធរសុខាភិបាលបញ្ជារឲ្យលោកអ្នកស្នាក់នៅឲ្យឆ្ងាយពីមនុស្សដទៃ លោកអ្នកត្រូវតែគោរពធ្វើតាម។

## តើអ្វីនឹងកើតចំពោះខ្ញុំ បើគេដាក់ខ្ញុំឲ្យនៅឯកានោះ ?

លោកអ្នកនឹងទទួលការព្យាបាលនៅលោកអ្នកឈឺ។ លោកអ្នកអាចទទួលការព្យាបាលនៅ :

- ផ្ទះរបស់លោកអ្នក,
- មន្ទីរពេទ្យ, ឬ
- មន្ទីរព្យាបាល។



អ្នកជម្ងឺដែលបានដាក់ឲ្យនៅឯកា*ត្រូវតែ*ស្នាក់នៅកន្លែងដាក់នោះ។ មានតែអ្នកផ្តល់ការព្យាបាលប៉ុណ្ណោះ អនុញ្ញាតឲ្យចូលទីកន្លែងនោះ។

## អ្វីទៅ*ការដាក់ឲ្យនៅដាច់ពីគេ*នោះ ?

ការដាក់ឲ្យនៅដាច់ពីគេគឺជាការបំបែកមនុស្សដែលមានការប៉ះពាល់ជាមួយមនុស្សឈឺចេញពីមនុស្សដទៃដែល មិនមានជម្ងឺ។

ការដាក់ឲ្យនៅដាច់ពីគេគឺប្រើឡើង សំរាប់តាមពិនិត្យមើលមនុស្សដែល មិនទាន់ឈឺ ប៉ុន្តែប្រហែលជាអាច ឈឺ ហើយកុំឲ្យមេរោគនោះរាលដាល ដល់អ្នកដទៃ។




## តើខ្ញុំ*ត្រូវតែ*នៅឲ្យដាច់ពីគេឬ ?

បាទ/ចាស។ បើសិនជាអាជ្ញាធរសុខាភិបាលគិតថា លោកអ្នកប្រហែលជាមានការប៉ះពាល់ជាមួយនិងមេរោគឆ្លង, អាជ្ញាធរអាចចេញបទបញ្ជារឲ្យលោកអ្នកស្នាក់នៅឲ្យឆ្ងាយពីមនុស្សដទៃ។

## តើអ្វីនឹងកើតមានឡើងចំពោះខ្ញុំ បើសិនជាគេដាក់ខ្ញុំឲ្យនៅដាច់ពីគេនោះ ?

លោកអ្នកប្រហែលជាស្នើសុំអោយ :

- នៅក្នុងផ្ទះ,
- ស្នាក់នៅឲ្យឆ្ងាយពីអ្នកដទៃ,
- រកមើលរោគសញ្ញាដោយខ្លួនឯង, ហើយ
- ទូរស័ព្ទទៅវេជ្ជបណ្ឌិត បើសិនជាលោកអ្នកមានរោគសញ្ញា។

## តើការដាក់នៅឲ្យឯកានិងការដាក់ឲ្យនៅដាច់ពីគេពិតជាការពារមនុស្សមិនឲ្យឈឺចាប់បានឬ ?

បាន។ នៅសហរដ្ឋអាមេរិកក្នុងឆ្នាំ 2003, ការដាក់ឲ្យនៅឯកានិងការដាក់ឲ្យនៅដាច់ពីគេអាចទប់ស្កាត់ការ រាលដាលនៃមេរោគឆ្លងនិងមេរោគសាហាវ SARS (សារស៍)។ ធ្វើបែបនេះជួយឲ្យមនុស្សមានសុខភាពល្អ ទោះបីជាគ្មានការព្យាបាលឲ្យជាក៏ដោយ, ថ្នាំ វ៉ាក់សាំង ឬថ្នាំពេទ្យពិសេសដែលមានសំរាប់ប្រើប្រាស់។

## សំរាប់ព័ត៌មានបន្ថែម...

ទូរស័ព្ទទៅ CDC (Centers for Disease Control) សំរាប់ព័ត៌មានជាភាសាអង់គ្លេស :

800-CDC-INFO (800-232-4636)
888-232-6348 (TTY)

ឬទស្សនាគេហទំព័រ : www.bt.cdc.gov/ncidod
www.dhs.ca.gov/epo